**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣ ❁ ៥

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

ថ្ងៃព្រហ ៤ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង
## ស្តីពីស្ថានភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរដូវប្រាំងឆ្នាំ២០២០

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានកែលម្អ និងសាងសង់រោងចក្រផលិតទឹកស្អាតថ្មីៗជាបន្តបន្ទាប់ ជាមួយនឹងការពង្រីកបណ្តាញចែកចាយ ដើម្បីសម្រេចបាននូវការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចិរភាពឆ្នាំ២០១៦-២០៣០ របស់រាជរដ្ឋាភិបាល។

បច្ចុប្បន្ននេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានរោងចក្រផលិតទឹកស្អាតសរុបចំនួន ៤ ផលិតទឹកស្អាតបានជាមធ្យម ៦០០.០០០ម៣/ថ្ងៃ។ ក៏ប៉ុន្តែជាក់ស្តែង ជាមួយនឹងការរីកលូតលាស់នៃរាជធានីភ្នំពេញនិងកំណើនប្រជាជន ធ្វើឲ្យតម្រូវការទឹកស្អាតបានកើនឡើងខ្ពស់ដល់ប្រមាណជា ៧០០.០០០ ម៣/ថ្ងៃ ដែលធ្វើឲ្យមានកង្វះទឹកស្អាតសំរាប់ចែកចាយ ជាពិសេសតំបន់ជាយក្រុងក្នុងម៉ោងមានតម្រូវការទឹកខ្ពស់។ ដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការទឹកស្អាតនេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញកំពុងបន្តសាងសង់បន្ថែមនូវរោងចក្រផលិតទឹកស្អាតថ្មីមួយទៀតនៅបាក់ខែង ដែលនឹងអាចផលិតទឹកស្អាតបាន ៣៩០.០០០ម៣/ថ្ងៃ ក្នុងឆ្នាំ២០២៣។

ដោយពិនិត្យឃើញថា នារដូវប្រាំងនេះ តម្រូវការទឹកនឹងកាន់តែកើនឡើង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមអំពាវនាវដល់អតិថិជនទាំងអស់ ទាំងក្នុងរាជធានីភ្នំពេញនិងទីក្រុងតាខ្មៅ មេត្តាជួយសន្សំសំចៃទឹកស្អាត ដើម្បីបានចែករំលែកទៅដល់អតិថិជនផ្សេងទៀត ពិសេសតំបន់ជាយក្រុង ដោយមេត្តាកុំប្រើប្រាស់ទឹកស្អាតសម្រាប់បាញ់លាងសម្អាតផ្ទះ មេត្តាកាត់បន្ថយការស្រោចសួននិងលាងយានយន្ត ជាដើម។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមថ្លែងអំណរគុណ និងសង្ឃឹម ព្រមទាំងជឿជាក់យ៉ាងមុតមាំក្នុងកិច្ចជួយសហការដោយក្តីអនុគ្រោះពីសំណាក់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក-លោកស្រី។៚

អាស័យដ្ឋាន៖ លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ៖ ៨៥៥(២៣)៧២៤០៤៦ Email: admin@ppwsa.com.kh